# រឿងនិស្សិតឈ្មោះគំរក់

( ចាក នា. ឯ. )

( អាក្រក់ចុះឱ្យតែល្អ ក្រចុះឱ្យតែមាន )

កាល កន្លងទៅយូរមកហើយ ព្រះពោធិសត្វ ទ្រង់ព្រះជាតិជាអាចារ្យទិសាបាមោក្ខ មាននាមល្បីល្បាញក្នុងកត្តសិលា តែងបង្រៀនកូនសិស្ស ៥០០ នាក់ ជានិច្ចរាល់ថ្ងៃ ។

កាលនោះ មាននិស្សិតម្នាក់ឈ្មោះ គំរក់ ជាឈ្មោះកំណើត ដែលមាតា បិតាដាក់ឱ្យ( បាបកៈបាលីថា ) នៅរៀនក្នុងសំណាក់ព្រះពោធិសត្វនោះ ។ រាល់តែថ្ងៃ និស្សិតទាំងឡាយជាគូកន នាំគ្នាហៅលេងសើចថា អាគំរក់ៗ ដូច្នេះ ព្រះពោធិសត្វ ក៏លោកហៅថាគំរក់ដូច្នោះដែរ ព្រោះជាឈ្មោះស្រាប់ទៅហើយ ។

និស្សិតគំរក់នោះ នឹកអន់ចិត្តនឹងឈ្មោះខ្លួនមិនល្អ ក៏ចូលទៅសុំព្រះពោធិសត្វ ជាអាចារ្យផ្លាស់ឈ្មោះឱ្យ។ ព្រះពោធិសត្វថា បើដូច្នោះ ឯងចូលដើរទៅក្នុងនិគមជនបទ រាជធានីស្វែងរកឈ្មោះដែលល្អ ប្រកបដោយសិរីសួស្តី ជ័យមង្គលរបស់បុគ្គលណាមួយ ដែលជាទីពេញចិត្តរបស់ឯងឱ្យបានមក ចាំអញផ្លាស់ឈ្មោះឱ្យ។

និស្សិតគំរក់ ធ្វើតាមពាក្យអាចារ្យ រៀបចំដំណើរថ្វាយបង្គំលា ត្រេចចរទៅក្នុងនិគមជនបទ រាជធានីផ្សេងៗ ដើម្បីស្វែងរកឈ្មោះឱ្យបានល្អ ក៏បានទៅដល់នគរមួយ ជួបនឹង អ្នកនគរកំពុងហែ សពទៅព្រៃស្មសាន ទើបនិស្សិតគំរក់សួរគេថា ៖

សូមទោស អ្វីឈ្មោះនេះស្លាប់អ្នក !? គេប្រាប់ថាឈ្មោះ រស់ ។ (ជីវកៈ ថាបាលី) បើឈ្មោះអើ ! ថាមាត់លាន់គំរក់និស្សិត រស់ ហើយម្តេចក៏ស្លាប់ ? គេថានែ នេះ ! សត្វមនុស្សរបស់ធម្មតារ បើទុកជាឈ្មោះ រស់ ក៏ដោយឈ្មោះ កើតក៏ដោយឈ្មោះជាក៏ដោយ មិនអាចជៀសពីការ ចាស់ ឈឺ ស្លាប់ ទេ ។

និស្សិតគំរក់ ស្តាប់ពាក្យគេហើយ អស់សង្ឃឹមរវើយគំនិត ក៏ដើរឈៀងចូលទៅភូមិមួយ ឃើញនាយថៅហ្វាយ ម្នាក់កំពុងវាយសំពងទាសី ដែលខ្ជះខ្ជាយ ធ្វើឱ្យបាត់ទ្រព្យរបស់គេ ។ និស្សិតគំរក់ឃើញហើយ សួរថា នាងនេះមានទោសដូចម្តេច បានជាលោកវាយដល់ម្លឹង ? គេប្រាប់ថា បានជាវាយព្រោះវាខ្ជះខ្ជាយ មិនចេះថែរក្សាទ្រព្យសម្បត្តិ ។

និស្សិតគំរក់សួរថា ចុះនាងនេះឈ្មោះអ្វី ? គេប្រាប់ថាឈ្មោះរក្សាទ្រព្យ បាលីថា ធន)បាលី ។( ចុះ បើឈ្មោះល្អម្លឹង ៗ ក៏មិនចេះថែរក្សាទ្រព្យ ? គេប្រាប់ថា នាងឯងកុំសង្ស័យឈ្មោះនោះ គេគ្រាន់តែកំណត់ឱ្យងាយស្គាល់ ងាយចំណាំគ្នាទៅវិញ ទៅមកប៉ុណ្ណោះទេ មិនមែនឈ្មោះឱ្យសុខទុក្ខបានឡើយ ។

និស្សិតគំរក់ឮ ហើយរឹតស្មើយគំនិត ក្នុងការស្វែងរកឈ្មោះល្អ ក៏ត្រលប់ទៅផ្ទះវិញ ដល់ពាក់កណ្ដាលផ្លូវ ឃើញបុរសម្នាក់ដើរវិលចុះ វិលឡើង ក៏សួរថា អ្នកដើរវិលវល់មានការអ្វី ? គេប្រាប់ថា ខ្ញុំវង្វេងផ្លូវ ។ និស្សិតគំរក់ ក៏សួរចង់ដឹងឈ្មោះអ្នកនោះទៀត គេប្រាប់ថា ខ្ញុំឈ្មោះអ្នកស្គាល់ផ្លូវ ( បន្ថកៈថា បាលី ) ចុះឈ្មោះចំណាប់ម្លឹង ម្ដេចក៏រកផ្លូវមិនឃើញ ? គេឆ្លើយតបវិញថា សំខាន់អ្វីត្រង់ឈ្មោះស្រេចតែនឹងខ្ញុំវង្វេង អ្នកឯងក៏ឆោតម្ល៉េះ ។

និស្សិតគំរក់ ត្រូវគេស្ដីឱ្យថាឆោត ក៏លែងស្វែងរកឈ្មោះទៀត ត្រលប់ទៅកាន់សំណាក់លោកអាចារ្យវិញ ។

ព្រះពោធិសត្វ ជាអាចារ្យសួរថា ម៉េចឯងទៅរកឈ្មោះល្អបានហើយឬនៅ ? និស្សិតគំរក់ថា ឥតអំពើទេ ដើរទៅឱ្យតែខាតរៀន អាឈ្មោះ រស់ បែរជាងាប់ មីឈ្មោះ រក្សាទ្រព្យ បែរជាធ្វើឱ្យបាត់ទ្រព្យគេ ត្រូវដំបង អាឈ្មោះ ស្គាល់ផ្លូវ ទៅជាវង្វេងរកផ្លូវទៅផ្ទះមិនឃើញ ។ ខ្ញុំបាទឈប់ផ្លាស់ឈ្មោះហើយ ម៉ែឪខ្ញុំឱ្យមកយ៉ាងណានៅយ៉ាងនោះចុះ ។

ព្រះពោធិសត្វ ឮដូច្នោះហើយ ក៏សូត្រពាក្យស្លោកថា

**ជីវកញ្ច មតំ ទិស្វា ធនបាលីញ្ច ទុគ្គតំ**
**បន្ថកញ្ច វនេ មុឡ្ហំ បាបកោ បុន វា គតោ ។**

សេចក្ដី ថា និស្សិតឈ្មោះ គំរក់ បានឃើញ អារស់ វាស្លាប់ មីរក្សាទ្រព្យ វាខ្វះខ្វាយ អាស្គាល់ផ្លូវ វាវង្វេងក្នុងព្រៃ ក៏ត្រលប់មកវិញបានឈ្មោះ គំរក់ ៗ ដដែល ។ តាំងពីពេលនោះ ដរាបទៅ និស្សិតគំរក់លែងគិតគូ ត្រង់ឈ្មោះ គិតតែខំរៀនសូត្រ ដរាបដល់បានសំរេចវិជ្ជា តាមបំណងរបស់ខ្លួនហោង ។

សូមអស់លោកអ្នកអនុមោទនា !       (ចប់)